01653695

F32

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្តកណ្តាល

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 03-Sep-2020, 14:45
CMS/CFO: Sann Rada

លេខ ៥៨៣ អ.ក/២០

# សេចក្តីជូនព័ត៌មាន

## របស់អ្នកនាំពាក្យអយ្យការ អមសាលាដំបូងខេត្តកណ្តាល
## ក្នុងព្រឹត្តការណ៍មរណភាពរបស់ទណ្ឌិត កាំង ហ្កេកអ៊ាវ ហៅ ឌុច

អ្នកនាំពាក្យអយ្យការ អមសាលាដំបូងខេត្តកណ្តាល សូមជម្រាបជូនសាធារណជនជាតិ និងអន្តរជាតិ ឱ្យបានជ្រាបថា៖ នៅព្រឹកថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០ នេះ ទណ្ឌិត **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** អតីតមេគុកទួលស្លែងក្នុងរបបខ្មែរក្រហម បានទទួលមរណភាព នៅមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត នៅវេលាម៉ោង ០០៖៥១នាទី រំលងអាធ្រាតឈានចូលថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០។

ទណ្ឌិត **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** កើតនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៤២ នៅភូមិពៅវើយ ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ សញ្ជាតិខ្មែរ មុខរបរគ្រូបង្រៀន ជាប្រធានមន្ទីរសន្តិសុខ ស-២១។ គាត់ត្រូវបានចាប់ និងឃុំខ្លួន នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ ហើយនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ ត្រូវបានផ្ទេរមកឃុំខ្លួន ក្នុងមន្ទីរឃុំឃាំង អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ពីបទ៖ **ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** កម្រិតទោសមួយជីវិត។

នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៣ អង្គជំនុំជម្រះតុលាការកំពូល បានចេញសាលដីកាសម្រេចផ្តន្ទាទោស **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** ដាក់ពន្ធនាគារអស់មួយជីវិត គាត់ត្រូវបានបញ្ជូនមកពន្ធនាគារខេត្ត-កណ្តាល នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ ដើម្បីអនុវត្តទោស។ គិតមកដល់ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០ ទណ្ឌិត **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** ត្រូវបានឃុំខ្លួននៅពន្ធនាគារខេត្តកណ្តាល អស់រយៈពេល ០៧ឆ្នាំ ២ខែ និង២៥ថ្ងៃ ។

ក្រោមការអនុវត្តទោសនៅពន្ធនាគារខេត្តកណ្តាល ទណ្ឌិត **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** ស្ថិតក្នុងសភាពទន់ខ្សោយ ជាមនុស្សចាស់ជរាក្នុងវ័យ៧៨ឆ្នាំ ដែលសុខភាពរបស់គាត់ស្ថិតក្នុងសភាពចុះទ្រុឌទ្រោមខ្លាំង ដោយទទួលរងបញ្ហាសុខភាពរាំរ៉ៃជាច្រើន។ ទណ្ឌិត **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** ធ្លាប់បានបញ្ជូនទៅពិនិត្យព្យាបាលនៅមន្ទីរពេទ្យក្រៅពន្ធនាគារចំនួន ០៤ លើក៖

- **លើកទី១៖** ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៨ បញ្ជូនទៅមន្ទីរពេទ្យបង្អែកជ័យជំនះខេត្តកណ្តាល ដោយមានអាការៈហត់ខ្លាំង លោកគ្រូពេទ្យបង្អែកជ័យជំនះ បញ្ជូនបន្តទៅមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៨ ហើយបានបញ្ជូនមកអង្គភាពពន្ធនាគារវិញនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨។
- **លើកទី២៖** ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៨ បញ្ជូនទៅមន្ទីរពេទ្យបង្អែកជ័យជំនះខេត្តកណ្តាល និងបញ្ជូនបន្តទៅមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត ដោយមានអាការៈចុកត្រង់តម្រងនោម (ស្ទះនោម) ហើយបានបញ្ជូនមកអង្គភាពពន្ធនាគារវិញនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨។



អាស័យដ្ឋាន៖ ផ្លូវជាតិលេខ២ ភូមិតាខ្មៅ២ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល
Address: National Road2, Phum Takhmao2, Sangkat Takhmao, Takhmao City, Kandal Province

- **លើកទី៣៖** ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៩ បញ្ជូនទៅមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត ដោយអាការៈហើមជើង ក្រោយបានពិនិត្យរួច បានបញ្ជូនមកអង្គភាពពន្ធនាគារវិញ។
- **លើកទី៤៖** ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០ បញ្ជូនទៅមន្ទីរពេទ្យបង្អែកជ័យជំនះខេត្តកណ្ដាល និងបញ្ជូនបន្តទៅមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត ដោយមានអាការៈហត់ខ្លាំង បន្ទាប់ពីទទួលការព្យាបាល ក៏ទទួលមរណភាពនៅវេលាម៉ោង ០០៖៥១នាទីរំលងអាធ្រាតឈានចូលថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០ តែម្ដង។

អ្នកនាំពាក្យអយ្យការអមសាលាដំបូងខេត្តកណ្ដាល សូមជូនដំណឹងថា ទណ្ឌិត **គាំង ហ្គេកអ៊ាវ** ហៅ **ឌុច** បានទទួលមរណភាពហើយ។ ក្រោមការដឹកនាំរបស់អយ្យការ អមសាលាដំបូងខេត្តកណ្ដាល ដោយមានការចូលរួមជាមួយមន្ត្រីពន្ធនាគារ មន្ត្រីសុខាភិបាល ក្រុមគ្រូពេទ្យកោសលវិច័យ និងមន្ត្រីពាក់ព័ន្ធទាំងអស់ ដោយធ្វើការយ៉ាងយកចិត្តទុកដាក់ អង្កេតលើករណីមរណភាពរបស់ទណ្ឌិតរូបនេះ ជាលទ្ធផលទទួលបាន ការស្លាប់នេះបណ្ដាលមកពីជំងឺប្រចាំកាយ (រលាកទងសួត និងជំងឺសួតធ្ងន់ធ្ងរ) ។ ក្រោយពីពិនិត្យចប់សព្វគ្រប់មន្ត្រីជំនាញយើងទាំងអស់បានធ្វើការប្រគល់សាកសពទៅឲ្យក្រុមគ្រួសារ ដើម្បីធ្វើបុណ្យតាមប្រពៃណី ។

អាស្រ័យហេតុនេះ សូមសាធារណជនជាតិ និងអន្តរជាតិទាំងអស់ ជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ១៥កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

កណ្ដាល, ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០

**អ្នកនាំពាក្យអយ្យការ អមសាលាដំបូងខេត្តកណ្ដាល**